# Alameda County Behavioral Health Care Services

## ក្រដាសផ្តល់ពត៌មានអំពីថ្នាំពេទ្យ: **ថ្នាំរំងាប់អារម្មណ៍/Mood Stabilizers**

[ ] lithium [ ] carbamazepine (Tegretol)

[ ] valproic acid/divalproex (Depakote)

ថ្នាំរំងាប់អារម្មណ៍គឺជាថ្នាំប្រើសំរាប់ព្យាបាលរោគព្រួយចិត្ត(គិតច្រើននិយាយច្រើន) ដើម្បីរំងាប់អារម្មណ៍ និងបន្ថយសកម្មភាពដែលផ្រួលហួសពីធម្មតា គិតច្រើន សំដីញាប់ ការរំជួលចិត្ត និងការដេកមិនលក់។ ម្យ៉ាងទៀត ថ្នាំនេះគេយកមកប្រើសំរាប់ព្យាបាលរោគព្រួយចិត្តដែលលប់មកវិញ និងបង្កើនប្រសិទ្ធិភាពនៃថ្នាំដទៃទៀត។

| **មានជាទូទៅ** | **មិនសូវមាន** | **កម្រមាន** |
|---|---|---|
| ការងុយងោក | កន្ទួល | បញ្ហាឈឺថ្លើម |
| ឈឺក្បាល | ជ្រុះសក់ | ហើមមុខ ឬហើមជើង |
| ឈឺក្រពះ | ទម្ងន់ឡើងចុះ | ចង្វាក់បេះដូងលោតខុសធម្មតា |
| ការចង្អោរ | វិលមុខ | បញ្ហាក្រពេញ |
| ការញ័រញាក់ | ការវង្វេងវង្វាន់ | ចំនួនគ្រាប់ឈាមចុះទាប (ខ្វះឈាម) |
| ផិងផោង | ស្រវាំងភ្នែក/មើលឃើញរូបពីរ | បញ្ហាឈឺថ្លើម |
| នោមច្រើន | ក្រពេញកប្តូរទំហំ | ចង្វាក់បេះដូងលោតខុសធម្មតា |
| | | ការហើមដៃ/ជើង |
| | | មុខការនៃតម្រងនោមចុះថយ |
| | | ស្រេកទឹកយ៉ាងខ្លាំង/នោមច្រើន |

ថ្នាំទាំងនេះគេអាចវាស់កំរិតរបស់វានៅក្នុងឈាមរបស់អ្នក ដើម្បីបញ្ជាក់កំរិតរបស់វាឲ្យបានត្រឹមត្រូវ។ ការចាប់ផ្តើមដំបូង ការធ្វើតេសឈាមត្រូវតែធ្វើជាច្រើនដង នៅពេលគេកំពុងបែបេកកំរិតថ្នាំ។

ថ្នាំទាំងនេះត្រូវតែលេបទៅតាមបញ្ជាគ្រូពេទ្យ ដោយមិនត្រូវអាក់ខានលេប ឬលេបលើសកំណត់ឡើយ។ ការអាក់ខានលេបថ្នាំ ឬលេបថ្នាំហួសកំណត់ អាចផ្លាស់ប្តូរកំរិតថ្នាំនៅក្នុងឈាមរបស់អ្នក។ គ្រូពេទ្យរបស់អ្នកនឹងត្រួតពិនិត្យកំរិតឈាមជាមួយនឹងអ្នក។

**ដោយសារតែថ្នាំនេះវាអាចបណ្តាលឲ្យក្មេងកើតមកមានបញ្ហា ជាការសំខាន់ណាស់ដែលអ្នកត្រូវតែជំរាបដល់គ្រូពេទ្យរបស់អ្នក បើសិនជាអ្នកមានផ្ទៃពោះ ឬគិតចង់បានកូន។**